# ឧបករណ៍ដែលអាចយកមកប្រើប្រាស់សម្រាប់ការវិភាគទំនាស់ដោយមានការចូលរួម

ឧបករណ៍វិភាគតាមបែបចូលរួមជាច្រើនប្រភេទ ត្រូវបានបង្កើតឡើងដោយអង្គការក្នុងស្រុក និងអន្តរជាតិ ដែលជាអ្នកអនុវត្តកម្មវិធីកសាងសន្តិភាព ហើយនឹងត្រូវបានយកមកប្រើប្រាស់ជាសកល (GPPAC 2015)។ ឧបករណ៍ទាំងនេះត្រូវបានគេចាត់ជាក្រុម ដោយយោងទៅតាមគោលបំណងចំបងៗរបស់វា និងចំណុចសំខាន់នៃការវិភាគ។ ឧបករណ៍មួយចំនួនត្រូវបានជ្រើសរើសយកមកបង្ហាញ ដោយបញ្ជាក់នូវគោលបំណង និងអត្ថប្រយោជន៍ ដូចខាងក្រោម៖

| ឈ្មោះឧបករណ៍ | គោលបំណង | អត្ថប្រយោជន៍ |
|---|---|---|
| ត្រីកោណ ABC<br>ABC Triangle | • ស្វែងយល់ពីបរិបទទំនាស់ តួអង្គសំខាន់ៗ អាកប្បកិរិយា និងឥរិយាបថរបស់ពួកគេ<br>• ប្រើនៅពេលចាប់ផ្ដើមអន្តរាគមន៍របស់ភាគីទី៣ ដើម្បីកំណត់កត្តាបង្កឲ្យមានទំនាស់នៃភាគីទំនាស់ និងអ្វីជាកត្តាដែលអាចចូលរួមចំណែកដោះស្រាយតាមរយៈអន្តរាគមន៍ | • បង្ហាញពីទំនាក់ទំនង និងអន្តរអំពើទៅវិញទៅមកនៃអាកប្បកិរិយា ឥរិយាបថ និង បរិបទ |
| ផែនទីតួអង្គ និងអ្នកពាក់ព័ន្ធ<br>Actors and Stakeholders Mapping | • ផ្ដល់ទិដ្ឋភាពទូទៅនៃភាគីទំនាស់ និងអ្នកពាក់ព័ន្ធសំខាន់ៗ<br>    ○ អំណាច/ឥទ្ធិពលរបស់ពួកគេ និង<br>    ○ ទំនាក់ទំនងរបស់ពួកគេ | • បង្ហាញឲ្យឃើញពីទំនាក់ទំនងអំណាច និងភាពមិនស្មើគ្នារវាងភាគីទំនាស់<br>• ជួយកំណត់ចំណុចចាប់ផ្ដើមនៃអន្តរាគមន៍និងតួអង្គដែលមានសក្ដានុពល<br>• បញ្ជាក់ពីគោលជំហរ និងតួនាទីរបស់ស្ថាប័ន ជាពិសេសវាមានសារសំខាន់បំផុតនៅពេលចាប់ផ្ដើម |
| ទំនាស់ខ្លឹមបារាំង<br>Conflict Union | • (មើលកាន់តែលម្អិត) ដោយប្រើសំណួរសំខាន់ៗមួយចំនួនស្ដីពីទំនាស់ដូចជា តម្រូវការ ផលប្រយោជន៍ និងមុខងារ។ វាត្រូវបានប្រើប្រាស់ក្នុងការរៀបចំអន្តរាគមន៍របស់ភាគីទី៣។ | • បង្ហាញពីភាពខុសគ្នា និងទំនាក់ទំនងរវាងមុខងារ ផលប្រយោជន៍ និងតម្រូវការ<br>• ជួយអ្នកឲ្យយល់ពីចរិកលក្ខណៈនៃទំនាស់រ៉ាំរ៉ៃដែលមានរយៈពេលយូរ |
| ទំនាស់ពីរ៉ាមីត<br>Conflict Pyramid | • ផ្ដល់ទិដ្ឋភាពទូទៅពីតួអង្គ និងអ្នកពាក់ព័ន្ធសំខាន់ៗដែលទាក់ទងនឹងការប្រែប្រួលនៃទំនាស់ ដោយយោងតាមអំណាចផ្លូវការ/ស្របច្បាប់របស់ពួកគេ ជះឥទ្ធិពលលើសកម្មភាពទំនាស់ (Conflict dynamics)<br>• សង្កត់ធ្ងន់លើតម្រូវការសម្រាប់ទំនាក់ទំនងដោយផ្ទាល់ និងដោយប្រយោលដើម្បី *(ភាពជោគជ័យ)* នៃការផ្លាស់ប្ដូរទំនាស់ | • កំណត់តួអង្គសំខាន់ៗ និងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិតនយោបាយ<br>• កំណត់សម្ព័ន្ធមិត្ត និងអ្នកសហការ ដែលមានសក្ដានុពលនៅគ្រប់កម្រិតដឹកនាំ |
| ជំហ៊ាននៃទំនាស់<br>Conflict Stages | • កំណត់សកម្មភាពទំនាស់ និងទំនោរនៃការប្រែប្រួល (រីករាលដាល/ថយចុះ) នៃទំនាស់នាពេលខាងមុខ | • កំណត់វដ្ដ និងដំណាក់កាលនៃការរីករាលដាល និងថយចុះនៃទំនាស់<br>• កំណត់ទំនោរនៃការរីករាលដាលនៃទំនាស់នាពេលខាងមុខ ដើម្បីបង្ការមិនឲ្យវាកើតមានឡើង (ផ្ដល់ការព្រមានឲ្យបានលឿន និងឆ្លើយតបបានលឿន)<br>• ជួយពិភាក្សាពីស្ថានភាពបច្ចុប្បន្ន |

| ឈ្មោះឧបករណ៍ | គោលបំណង | អត្ថប្រយោជន៍ |
| --- | --- | --- |
| បន្ទាត់ពេលវេលា<br>Conflict Timeline | • ប្រើប្រាស់ក្នុងអន្តរាគមន៍សម្រាប់ភាគីទី៣ ដូចជា ដំណើរការសម្របសម្រួល ឬ សម្រាប់ប្រជាពលរដ្ឋ<br>• បង្ហាញពីការគិតផ្សេងគ្នានៃប្រវត្តិសាស្ត្រទំនាស់ និងសកម្មភាពទំនាស់ | • សម្របសម្រួលការពិភាក្សាដែលមានគំនិតយោបល់ផ្សេងគ្នា ដោយផ្អែកលើការបកស្រាយខុសគ្នាលើប្រវត្តិសាស្ត្រ<br>• ចូលរួមជជែកពិភាក្សាស្តីពីគំនិតផ្សេងគ្នានៃព្រឹត្តិការប្រវត្តិសាស្ត្រ<br>• ជួយភាគីទំនាស់យល់ពីការគិតរបស់ពួកគេថាគ្រាន់តែជាមួយផ្នែកនៃការពិតរបស់ប្រវត្តិសាស្ត្រតែប៉ុណ្ណោះ |
| ដើមឈើទំនាស់<br>Conflict Tree | • ផ្តល់ទិដ្ឋភាពទូទៅពីកត្តាទំនាស់ចំបងៗ (ឫសគល់នៃបញ្ហា បញ្ហាទំនាស់ និងផលជះរបស់វា) | • បង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធិ និងអន្តរអំពើនៃឫសគល់ទំនាស់ បញ្ហា និងផលជះរបស់វា<br>• ជួយចាត់អទិភាពសកម្មភាពមួយ ដែលអាចជួយដោះស្រាយបញ្ហាទំនាស់ |
| ឧបករណ៍មិនបង្កទំនាស់/ការវិភាគផលជះ<br>Do No Harm/Impact Analysis | • វាយតម្លៃបរិបទទំនាស់ (កត្តាបែកបាក់ និងកត្តាផ្សារភ្ជាប់) និង ផលជះអវិជ្ជមានដែល (ស្មានមិនដល់) របស់គម្រោង (សកម្មភាព/ដំណើរការលម្អិត) ទៅលើបរិបទទំនាស់ | • ជួយកាត់បន្ថយភាពស្មុគ្រស្មាញនៃទំនាស់<br>• ជួយកាត់បន្ថយផលជះអវិជ្ជមាន (ស្មានមិនដល់) ជាអប្បរមា និង បង្កើនផលជះវិជ្ជមាន (ដែលចង់បាន)របស់គម្រោង ឲ្យដល់កម្រិតអតិបរមា |
| Force Field Analysis | • ផ្តល់ទិដ្ឋភាពទូទៅទៅលើកត្តាបង្កឲ្យមានទំនាស់ និងកត្តាប្រឆាំងនឹងទំនាស់ | • ជួយរៀបចំព័ត៌មានស្តីពីស្ថានភាពទំនាស់បច្ចុប្បន្ន<br>• ផ្តល់នូវទិដ្ឋភាពកាន់តែច្បាស់ពីកត្តាបង្កឲ្យមានទំនាស់ និងកត្តាប្រឆាំងនឹងទំនាស់<br>• ជួយចាត់អទិភាព កត្តាបង្កឲ្យមានទំនាស់ និងប្រឆាំងនឹងទំនាស់ |
| តារាងផលប្រយោជន៍ តម្រូវការ និងភាពភ័យខ្លាច<br>Interests, Needs and Fears Chart | • (មើលកាន់តែលម្អិត) ដោយប្រើសំណួរសំខាន់ៗមួយចំនួនស្តីពីទំនាស់ដូចជា តម្រូវការ ផលប្រយោជន៍ និងមុខងារ។ វាត្រូវបានប្រើប្រាស់ក្នុងការរៀបចំអន្តរាគមន៍របស់ភាគីទី៣។ | • ជួយភាគីទំនាស់ឲ្យយល់ពីតម្រូវការ និងភាពភ័យខ្លាចដែលមិនអាចមើលឃើញនឹងភ្នែក ដែលនៅពីក្រោយផលប្រយោជន៍ និងមុខងារ<br>• បង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងអន្តរអំពើនៃបញ្ហាទំនាស់ បរិបទ និងតម្រូវការ និងផលប្រយោជន៍នៃភាគីទំនាស់ |
| ការវិភាគទំនាស់ជាលក្ខណៈប្រព័ន្ធ/ផែនទីប្រព័ន្ធ<br>Systemic Conflict Analysis/Systems Mapping | • កំណត់ចំណុចចាប់ផ្តើមជាយុទ្ធសាស្ត្រសម្រាប់យុទ្ធសាស្ត្រកសាងសន្តិភាព ឬកម្មវិធី<br>• ផ្តល់នូវការវិភាគជាលក្ខណៈមូលដ្ឋានសម្រាប់ការបង្កើតសេណារីយ៉ូ/ព្យាករណ៍ទំនាស់ ឬ វាយតម្លៃភាពប្រថុយប្រថាន | • ជួយដល់ការស្វែងយល់ និងពន្យល់ពីទំនាក់ទំនង/អន្តរអំពើ (ភាពត្រឹង/អូសបន្លាយ) នៃទំនាស់ហិង្សា និងសង្គម<br>• បន្តកំណត់សកម្មភាពទំនាស់ជាលក្ខណៈខ្សែត្រង់ និង បត់បែនឡើងចុះ ព្រមទាំងទំនាក់ទំនង និងសកម្មភាពនៃកត្តាទំនាស់ទាំងនេះ |